## Expressing dislikes 2A



ម្លិះ៖ ធារី កំពុងធ្វើអីហ្នឹង?

ធារី៖ កំពុងលាងចាន។ ហត់ដល់ហើយ។ ធ្វើម្ហូបហើយ ត្រូវលាងចានទៀត។

ម្លិះ៖ ធ្វើម្ហូបម្តងៗអីចឹងហើយ។ ស្រួលបំផុត មានតែទៅក្រៅញ៉ាំ។

ធារី៖ ខ្ញុំអត់ចូលចិត្តទៅញ៉ាំក្រៅទេ ព្រោះខ្លាចគេធ្វើគគ្រិច។ មិនមែនថាមិនចូលចិត្តធ្វើម្ហូបទេ គ្រាន់តែពេលខ្លះចានឆ្នាំងប្រឡាក់ច្រើនពេក។

ម្លិះ៖ ទុកឲ្យខ្ញុំលាងវិញណា។ ទៅសម្រាកទៅ។

ធារី៖ អរគុណ ម្លិះ។ អត់អីទេ ជិតរួចហើយ។ ឲ្យភ្ញៀវលាងចានម៉េចទេ!

| | |
|---|---|
| ម្លិះ, ធារី | female Cambodian names |
| លាងចាន | to do the dishes |
| ហត់ | tired |
| ដល់ហើយ | intensifier: very much, really, a lot |
| ម្តងៗ | every time |
| អីចឹង | like this, this way |
| ទៅក្រៅញ៉ាំ | to eat out |
| គគ្រិច | dirty, filthy, unhygienic |
| មិនមែនថាមិន ... | it's not that I don't ... |
| ប្រឡាក់ | dirty |
| ទុកឲ្យខ្ញុំធ្វើវិញ | let me do it |
| ជិតរួចហើយ | [I'm] almost finished |
| ឲ្យភ្ញៀវលាងចានម៉េចទេ! | Noone will let their guests do the dishes! |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ជនជាតិជប៉ុនតែងតែនិយាយពាក្យថា សុំទោស ជាញឹកញាប់។ ប៉ុន្តែ ជនជាតិខ្មែរមិនចូលចិត្តនិយាយថា សុំទោស នោះទេ ជាពិសេសពេលត្រូវនិយាយទៅកាន់អ្នកដែលក្មេងជាងឬឋានៈតូចជាង។ នេះជាទម្លាប់អាក្រក់មួយរបស់ជនជាតិខ្មែរ។

| | |
|---|---|
| ជប៉ុន | Japan, Japanese |
| ជាញឹកញាប់ | frequent(ly), often |
| ជាពិសេស | especially |
| ឋានៈតូចជាង | of lower social status |
| ទម្លាប់អាក្រក់ | bad habit |

## Additional dialogue

បូរ៉ា៖ តារា ទៅណាហ្នឹង?
តារា៖ ទៅបណ្ណាល័យ។ ទំនេរអត់? តស់ ទៅអានសៀវភៅជាមួយគ្នា។
បូរ៉ា៖ មុខខ្ញុំនឹងអានសៀវភៅ? ខ្ជិលអាំ។
តារា៖ ចឹ?
បូរ៉ា៖ មិនមែនថាមិនចូលចិត្តទេ។ ចូលចិត្តអានដែរ តែពិបាកត្រង់ ឆាប់ងងុយដេក។
តារា៖ មកពីមិនទាន់ទម្លាប់។ ទៅអត់?
បូរ៉ា៖ ទៅក៏ទៅ។

| | |
|---|---|
| បូរ៉ា, តារា | male Cambodian names |
| បណ្ណាល័យ | library |
| ទំនេរអត់? | Are you free? |
| តស់ | Come on! / Let's go! |
| មុខខ្ញុំនឹង ... ? | Can you imagine I will ... ? |
| ខ្ជិលអាំ = ខ្ជិលណាស់ | [I'm] very lazy |
| ចឹ = ម៉េច = ហេតុអី? | Why? |
| តែពិបាកត្រង់ | the problem is |
| ឆាប់ងងុយដេក | I get sleepy easily |
| មកពី | it's because |
| មិនទាន់ទម្លាប់ | to be not used to |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.